ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមហាផ្ទៃ
សាលាខេត្តកែប
លេខ០២៤.សសរ-ខក

# សេចក្តីសម្រេច
## ស្តីពី
## ការកែសម្រួលសមាសភាពគណៈកម្មការខេត្ត រៀបចំពិធីប្រណាំងទូកផ្កាចារសមុទ្រ

## អភិបាលខេត្តកែប

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០៩/៥៤២ ចុះថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០០៩ របស់ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ស្តីពីការត្រាស់បង្គាប់តែងតាំងជាអភិបាល នៃគណៈអភិបាលខេត្តកែប ។
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក។
- បានឃើញប្រកាសលេខ ៤២៤៧ ប្រក ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៩ របស់ក្រសួងមហាផ្ទៃ ស្តីពីការបង្កើតការិយាល័យចំណុះទីចាត់ការនៃសាលាខេត្ត ការបង្កើតការិយាល័យនៃសាលាក្រុង ការបង្កើតការិយាល័យនៃសាលាស្រុក និងការកំណត់តួនាទី ភារកិច្ច របៀបរបបការងារ នៃការិយាល័យទាំងនោះ ។
- បានឃើញប្រកាសលេខ ៣៤៣៣ ប្រក ចុះថ្ងៃទី ២២ ខែតុលា ឆ្នាំ ២០០៧ របស់ក្រសួងមហាផ្ទៃ ស្តីពីការបែងចែកតួនាទី ភារកិច្ច និងរបៀបរបបធ្វើការជូនអភិបាល និងអភិបាលរងក្រុងកែប ។
- យោងផែនការណែនាំ ស្តីពីការរៀបចំព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និង សំពះព្រះខែ អកអំបុក របស់គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ អន្តរជាតិ ។
- យោងសេចក្តីសម្រេចលេខ ០១៦ សសរ ចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០០៩ របស់សាលាខេត្តកែប ស្តីពីការបង្កើតគណៈកម្មការរៀបចំពិធីប្រណាំងទូកមុខសាលាខេត្ត ឆ្នាំ ២០០៩ ។
- ដើម្បីលើកកម្ពស់នូវតម្លៃវប្បធម៌ប្រពៃណីជាតិរបស់ប្រជាជនយើង ដែលមានតាំងពីយូរលង់មកហើយ និងបង្កការសប្បាយរីករាយជូនប្រជាជននៅខេត្តកែប ក៏ដូចជាភ្ញៀវទេសចរជាតិ និងអន្តរជាតិ ព្រមទាំងប្រជាជនទូទាំងប្រទេសផងដែរ ។
- យោងតាមការចាំបាច់

## <u>សម្រេច</u>

**<u>ប្រការ១:</u>** ត្រូវបានកែសម្រួលសមាសភាពគណៈកម្មការខេត្តរៀបចំការប្រណាំងទូកផ្កាចារសមុទ្រ ដែលមានសមាសភាពដូចខាងក្រោម :

| | | | |
|---|---|---|---|
| ១-លោក | **កែន សត្ថា** | អភិបាលរងខេត្ត | ជាប្រធាន |
| ២-លោក | **ហៀម ឃួន** | នាយករដ្ឋបាលសាលាខេត្ត | ជាអនុប្រធាន |
| ៣-លោក | **ទៅ សុខា** | ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត | ជាអនុប្រធាន |

| | | | | |
|---|---|---|---|---|
| ៤-លោកឧ.ត្រី | អ៊ុំ | សំអុល | ស្នងការនគរបាលខេត្ត | ជាអនុប្រធាន |
| ៥-លោកឧ.ត្រី | ជន | សុផល | មេបញ្ជាការតំបន់ប្រតិបត្តិការសឹកខេត្ត | ជាសមាជិក |
| ៦-លោកឧ.ត្រី | ឆា | គៀត | មេបញ្ជាការកងរាជអាវុធហត្ថខេត្ត | ជាសមាជិក |
| ៧-លោកវ.ទោ | ពេញ | ភារ៉ូ | មេបញ្ជាការវរៈសេនាតូចលេខ៤៣០ នគរបាលព្រំដែនទឹក | ជាសមាជិក |
| ៨-លោក | អ៊ុក | សាខន | ប្រធានមន្ទីរព័ត៌មានខេត្ត | ជាសមាជិក |
| ៩-លោក | ទួន | ច័ន្ទសុជាតា | ប្រធានមន្ទីរអប់រំ យុវជន និង កីឡាខេត្ត | ជាសមាជិក |
| ១០-លោក | ឆាយ | ខឿន | ប្រធានមន្ទីរទេសចរណ៍ខេត្ត | ជាសមាជិក |
| ១១-លោក | ម៉ែន | សុធីរ | ប្រធានមន្ទីរសុខាភិបាលខេត្ត | ជាសមាជិក |
| ១២-លោក | គង់ | ផែន | ប្រធានមន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ចខេត្ត | ជាសមាជិក |
| ១៣-លោក | គង់ | សុផល | ប្រធានមន្ទីរបរិស្ថានខេត្ត | ជាសមាជិក |
| ១៤-លោក | សាម | ឈូក | ប្រធានមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្ត | ជាសមាជិក |
| ១៥-លោក | ម៉ឹម | ទូច | ប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត | ជាសមាជិក |
| ១៦-លោក | ឆេង | ម៉ានី | ប្រធានមន្ទីរពាណិជ្ជកម្មខេត្ត | ជាសមាជិក |
| ១៧-លោក | ឡុង | សារឿន | ប្រធានមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត | ជាសមាជិក |
| ១៨-លោក | កែវ | ហុង | ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត | ជាសមាជិក |
| ១៩-លោកស្រី | អ៊ុល | តីរុណ | ប្រធានមន្ទីរកិច្ចការនារីខេត្ត | ជាសមាជិក |
| ២០-លោក | ផ្លោក | ថៃ | ប្រធានមន្ទីរកសិកម្មខេត្ត | ជាសមាជិក |
| ២១-លោក | ប៊ិញ | ជីវតុង | ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលខេត្ត | ជាសមាជិក |
| ២២-លោក | ហៀង | ម៉េង | ប្រធានមន្ទីរធនធានទឹក និងឧតុនិយមខេត្ត | ជាសមាជិក |
| ២៣-លោក | គង់ | សាវ៉ាត | ប្រធានមន្ទីរផែនការខេត្ត | ជាសមាជិក |
| ២៤-លោក | ឡឹក | ខាន់ | ប្រធានមន្ទីរធម្មការ និងសាសនាខេត្ត | ជាសមាជិក |
| ២៥-លោក | ឱត | ឡាយហ៊ាក | ប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត | ជាសមាជិក |
| ២៦-លោក | អ៊ុច | គីមស៊ាន | ប្រធានសាខាពន្ធដារខេត្ត | ជាសមាជិក |
| ២៧-លោក | ម៉ុក | សែន | ប្រធានមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្ត | ជាសមាជិក |
| ២៨-លោក | ចាន់ | សាម៉េង | ប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្ត | ជាសមាជិក |
| ២៩-លោក | ឆេព | យុទ្ធី | អភិបាលស្រុកដំណាក់ចង្អើរ | ជាសមាជិក |
| ៣០-លោក | ទិន | ទិនដា | អភិបាលក្រុងកែប | ជាសមាជិក |
| ៣១-លោក | ឈុប | សំអុន | ចៅសង្កាត់កែប | ជាសមាជិក |
| ៣២-លោក | តូច | សាម៉ន | ចៅសង្កាត់ព្រៃធំ | ជាសមាជិក |
| ៣៣-លោក | ម៉ី | លីន | មេឃុំអង្កោល | ជាសមាជិក |
| ៣៤-លោក | ភួយ | ចេងគង | មេឃុំអូរក្រសារ | ជាសមាជិក |
| ៣៥-លោក | លី | ហ៊ត | មេឃុំពងទឹក | ជាសមាជិក |

*ប្រការ២:* គណៈកម្មការខេត្ត មានភារកិច្ច ៖

-ដឹកនាំ ណែនាំចង្អុលការលើការងារចាត់ចែង រៀបចំត្រួតពិនិត្យស្ថានភាពទូទៅក្នុងពិធីប្រណាំងទូកទាំងមូល ទាំងទិដ្ឋភាពសណ្តាប់ធ្នាប់សាធារណៈ សោភណភាព របៀបរៀបរយសង្គម បរិយាកាសក្នុងពិធីប្រណាំងទូក និងទិដ្ឋភាពបច្ចេកទេស នៃការប្រណាំងទូកឱ្យទទួលបានលទ្ធផលល្អប្រសើរ ។

-សម្របសម្រួល និងជំរុញបណ្តាមន្ទីរ អង្គភាព វត្តអារាម សណ្ឋាគារ ផ្ទះសំណាក់ និងសប្បុរជនរៀបចំទូកផ្កាចារសមុទ្រ ដើម្បីចូលរួមប្រកួតអោយបានអធិកអធមសប្បាយរីករាយក្នុងបរិយាកាស សាមគ្គីភាព មិត្តភាព និងស្និទ្ធស្នាល ។

-ទំនាក់ទំនង និងគៀងគរ បណ្តាខេត្តនានា និងខេត្តសម្ព័ន្ធមិត្ត គៀនយ៉ាង (វៀតណាម) ដើម្បីបញ្ជូនទូកផ្កាចារសមុទ្រអោយមកចូលរួមឱ្យបានច្រើនកុះករ ។

-ធ្វើការទំនាក់ទំនង សហការល្អជាមួយក្រុមការងាររបស់ឯកឧត្តម **ចម ប្រសិទ្ធ** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម អំពីសំលៀកបំពាក់ រង្វាន់លើកទឹកចិត្ត ថវិកា និងសម្ភារៈផ្សេងៗទៀត ។

*ប្រការ៣:* ត្រូវបានបង្កើតអនុគណៈកម្មការនានាជាជំនួយការ ដែលមានសមាសភាព និងភារកិច្ចដូចខាងក្រោម ៖

**ក_អនុគណៈកម្មការរៀបចំទីតាំងទេនិការ និងទីតាំងប្រណាំងទូក**

**ក.១ សមាសភាព ៖**

| | | | | |
|---|---|---|---|---|
| ១- លោក | **ទៅ** | **សុខា** | ប្រធានមន្ទីរ ជនសស ខេត្ត | ជាប្រធាន |
| ២- លោក | **ម៉ម** | **ឆូច** | ប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត | ជាអនុប្រធាន |
| ៣-លោក | **ទេព** | **យុទ្ធី** | អភិបាលស្រុកដំណាក់ចង្អើរ | ជាសមាជិក |
| ៤- លោក | **ទិន** | **ទិនដា** | អភិបាលក្រុងកែប | ជាសមាជិក |
| ៥- លោក | **លី** | **សារឹម** | អភិបាលរងក្រុងកែប | ជាសមាជិក |
| ៦- លោក | **ជិន** | **សឿន** | នាយកទីចាត់ការអន្តរវិស័យសាលាខេត្ត | ជាសមាជិក |
| ៧- លោក | **អ៊ឹង** | **ទុន្នី** | នាយកទីចាត់ការផែនការ និងវិនិយោគសាលាខេត្ត | ជាសមាជិក |
| ៨- លោក | **នាយ** | **ខឿន** | ប្រធានមន្ទីរទេសចរណ៍ខេត្ត | ជាសមាជិក |
| ៩- លោក | **ឡឹក** | **ខាន់** | ប្រធានមន្ទីរធម្មការ និងសាសនាខេត្ត | ជាសមាជិក |
| ១០- លោក | **មុំ** | **ស៊ីថា** | អធិការនគរបាលក្រុងកែប | ជាសមាជិក |
| ១១-លោក | **ណុប** | **សំអុន** | ចៅសង្កាត់កែប | ជាសមាជិក |
| ១២-លោក | **តូច** | **សាម៉ន** | ចៅសង្កាត់ព្រៃធំ | ជាសមាជិក |
| ១៣-លោក | **ម៉ី** | **លីន** | មេឃុំអង្កោល | ជាសមាជិក |
| ១៤-លោក | **កួយ** | **ចេងគង** | មេឃុំអូរក្រសារ | ជាសមាជិក |
| ១៥-លោក | **លី** | **ហ៊ត** | មេឃុំពងទឹក | ជាសមាជិក |

**ក.២ ភារកិច្ច ៖**

-រៀបចំទីតាំងមុខសាលាខេត្ត ធានាបាននូវសោភណភាព អនាម័យ សំអាតទីធ្លាតាមបណ្តោយឆ្នេរ តាមដងផ្លូវសាធារណៈ មន្ទីរ អង្គភាព ភូមិដ្ឋាន គ្រប់ទីប្រជុំជន ផ្សារលក់ដូរទូទាំងខេត្តអោយបានសមរម្យ ដើម្បីអបអរសាទរក្នុងពិធីអុំទូក ប្រកបដោយបរិយាសកាសល្អប្រសើរ ។

-រៀបចំតូបលក់ដូរតាមបណ្តោយឆ្នេរខាងលើអោយបានស្អាត ធានាអោយបាននូវសណ្តាប់ធ្នាប់ល្អប្រសើរ។

-រៀបចំចំណតរថយន្ត ម៉ូតូ និងយានជំនិះគ្រប់ប្រភេទជូនសាធារណជន និងចំណតរថយន្តគណៈអធិបតីភ្ញៀវកិត្តិយស ដើម្បីធានាបាននូវសុវត្ថិភាពមួយរយភាគរយ ។

-រៀបចំសណ្តាប់ធ្នាប់ទូទៅ ធានាបាននូវការចូលរួមទស្សនារបស់សាធារណជនប្រកបដោយសុវត្ថិភាព និងសប្បាយរីករាយ ។

-រៀបចំទីកន្លែងដាក់បង្គន់អនាម័យនៅតាមទីសាធារណៈ ។

## ខ-អនុគណៈកម្មការពិធីការ និងផ្សព្វផ្សាយព័ត៌មាន

### ខ.១ សមាសភាព :

| | | | | |
|---|---|---|---|---|
| ១-លោក | អ៊ុក | សាខន | ប្រធានមន្ទីរព័ត៌មានខេត្ត | ជាប្រធាន |
| ២-លោក | ផ្លោក | ថៃ | ប្រធានមន្ទីរកសិកម្មខេត្ត | ជាអនុប្រធាន |
| ៣-លោក | គង់ | ផែន | ប្រធានមន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ចខេត្ត | ជាសមាជិក |
| ៤-លោក | គង់ | សាវ៉ាត | ប្រធានមន្ទីរផែនការខេត្ត | ជាសមាជិក |
| ៥-លោកស្រី | អ៊ុល | គីរុណា | ប្រធានមន្ទីរកិច្ចការនារីខេត្ត | ជាសមាជិក |
| ៦-លោក | នេខ | ម៉ានី | ប្រធានមន្ទីរពាណិជ្ជកម្មខេត្ត | ជាសមាជិក |
| ៧-លោក | សាម | ណូក | ប្រធានមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្ត | ជាសមាជិក |
| ៨-លោក | ខិត | ឡាយហារីក | ប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត | ជាសមាជិក |
| ៩-លោក | មិញ | ជីវគុន | ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលខេត្ត | ជាសមាជិក |
| ១០-លោក | ម៉ុក | សែន | ប្រធានមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្ត | ជាសមាជិក |
| ១១-លោក | ចាន់ | ថា | នាយកទីចាត់ការគ្រប់គ្រងធនធានមនុស្សសាលាខេត្ត | ជាសមាជិក |
| ១២-លោកស្រី | ខិត | សុខា | អភិបាលរងក្រុងកែប | ជាសមាជិក |
| ១៣-លោកស្រី | គីម | ចន្ធី | អភិបាលរងស្រុកដំណាក់ចង្អើរ | ជាសមាជិក |
| ១៤-លោក | ផូ | ស៊ីថា | អនុប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្ត | ជាសមាជិក |
| ១៥-លោក | ទ៉ែន | ហាន | អនុប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត | ជាសមាជិក |
| ១៦-លោកស្រី | ដួង | កែវចិន្តា | ប្រធានការិយាល័យ នៃមន្ទីរទេសចរណ៍ខេត្ត | ជាសមាជិក |
| ១៧-លោក | ណុប | សំអុន | ចៅសង្កាត់កែប | ជាសមាជិក |
| ១៨-លោក | តូច | សាម៉ន | ចៅសង្កាត់ព្រៃធំ | ជាសមាជិក |
| ១៩-លោក | ម៉ី | លីន | មេឃុំអង្កោល | ជាសមាជិក |
| ២០-លោក | កួយ | ចេងគង | មេឃុំអូរក្រសារ | ជាសមាជិក |
| ២១-លោក | លី | ហ៊ត | មេឃុំពងទឹក | ជាសមាជិក |

### ខ.២ ភារកិច្ច :

-រៀបចំសេចក្តីជូនដំណឹងផ្សព្វផ្សាយឱ្យបានទូលំទូលាយដល់អាជ្ញាធរគ្រប់លំដាប់ថ្នាក់ អង្គភាព សប្បុរសជន ភ្ញៀវជាតិ អន្តរជាតិ និងប្រជាជន អាជីវករទាំងអស់តាមប្រព័ន្ធវិទ្យុ ទូរទស្សន៍ ដើម្បីចូលរួមទស្សនាឱ្យបានច្រើនកុះករ ។

-ទំនាក់ទំនងប្រព័ន្ធផ្សព្វផ្សាយថ្នាក់ជាតិ ដូចជាវិទ្យុ ទូរទស្សន៍ ស៊ីធីអិន អាស៊ីអគ្នេយ៍ ទទក អប្សរា ប៉ុស្តិ៍លេខ ៣ ប៉ុស្តិ៍បាយ័ន ។ល។ ដើម្បីយកព័ត៌មានមកផ្សព្វផ្សាយអោយបានទូលំទូលាយ ។

-រៀបចំតុបតែងវេទិកា កន្លែងគណៈអធិបតី និងភ្ញៀវកិត្តិយសចូលរួម ។

-រៀបចំបដា ពាក្យស្លោក ទង់ជាតិ ទង់ជ្វាលា ( ដាក់តាមបណ្តោយឆ្នេរ និងតាមដងផ្លូវមុខសាលាខេត្ត)

រៀបចំឧឃ្លោសនស័ព្ទបំពងសំលេងក្នុងពិធីអោយបានអធិកអធម ។

-បដិសណ្ឋារកិច្ចគណៈអធិបតី ភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិ ។

**គ-អនុគណៈកម្មការចំណូល-ចំណាយ**

**គ.១ សមាសភាព :**

១- លោក **កែវ ហុង** ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត ជាប្រធាន

២- លោក **អ៊ុក ថា** នាយកទីចាត់ការហិរញ្ញវត្ថុសាលាខេត្ត ជាអនុប្រធាន

៣- លោក **ឃៀក សារ៉ន** អនុប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត ជាសមាជិក

៤- លោក **អ៊ុច គឹមស៊ាន** ប្រធានសាខាពន្ធដារខេត្ត ជាសមាជិក

៥- លោក **ព្រំ គន្ធី** នាយករងទីចាត់ការហិរញ្ញវត្ថុសាលាខេត្ត ជាសមាជិក

៦- លោក **គេង ហុកស៊ុី** ប្រធានការិយាល័យនៃមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តជាសមាជិក

**គ.២ ភារកិច្ច :**

-ទំនាក់ទំនង និងធ្វើសេចក្តីអំពាវនាវសុំការជួយឧបត្ថម្ភពីបណ្តាមន្ទីរ អង្គភាព អាជីវករ ពាណិជ្ជករ និងសប្បុរសជននានា ដោយមានបញ្ជីឈ្មោះសប្បុរសជន និងថវិកា សម្ភារៈ ដែលទទួលបានពីសប្បុរសជនទាំងអស់ ដើម្បីផ្សព្វផ្សាយតាមវិទ្យុ ។

-ធ្វើរបាយការណ៍ចំណូល-ចំណាយក្នុងអង្គពិធីទាំងមូល ជូនប្រធានគណៈកម្មការ និងអភិបាលខេត្ត ។

-ទទួលខុសត្រូវចាត់ចែងចំណូល និងចំណាយ នៃការរៀបចំពិធី និងរង្វាន់លើកទឹកចិត្តដល់កីឡាករ និងបោះពុម្ពទង់ជ័យលាភីជូនដល់កីឡាករ កីឡាការនីប្រណាំងទូកដែលទទួលបានជ័យលាភី និងកិច្ចការផ្សេងៗទៀតដែលពាក់ព័ន្ធដល់ការចំណាយ ។

**ឃ-អនុគណៈកម្មការបច្ចេកទេស និងរៀបចំកន្លែងស្នាក់នៅរបស់កីឡាករ**

**ឃ.១ សមាសភាព :**

១-លោក **ខួន ច័ន្ទសុជាតា** ប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ជាប្រធាន

២-លោក **ហៀង ម៉េង** ប្រធានមន្ទីរធនធានទឹក និងឧតុនិយមខេត្ត ជាអនុប្រធាន

៣-លោក **ចាន់ សាម៉េង** ប្រធានមន្ទីរសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទាខេត្តជាសមាជិក

៤-លោក **សុទ្ធ ពុទ្ធិម៉ានីន** អនុប្រធានមន្ទីរ ជនសស ខេត្ត ជាសមាជិក

៥-លោក **គីម សាខុំ** អនុប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ជាសមាជិក

៦-លោកវ.ទោ **ពេញ ភារ៉ូ** មេបញ្ជាការវរៈសេនាតូចលេខ៤៣០ នគរបាលព្រំដែនទឹក ជាសមាជិក

៧-លោក **នួន សេង** អនុប្រធានមន្ទីរសុខាភិបាលខេត្ត ជាសមាជិក

៨-លោក **លាម ផាន់ណា** ប្រធានការិ.នៃមន្ទីរកសិកម្មខេត្ត ជាសមាជិក

៩-លោក **គីន ផល្លា** នាយផ្នែករដ្ឋបាលជលផលកែប ជាសមាជិក

១០-លោក **ចក់ ស៊ីនាថ** នាយរងផ្នែករដ្ឋបាលជលផលកែប ជាសមាជិក

១១-លោក **ឆើម ណារ៉ុង** មន្ត្រីនៃមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ជាសមាជិក

ឃ.២ **ភារកិច្ច** :

-ជ្រើសរើសកំណត់ទីតាំង និងទទួលខុសត្រូវលើការស្នាក់នៅរបស់កីឡាករ ។

-ផ្សព្វផ្សាយព័ត៌មាន និងចលនាការចូលរួមទស្សនាអោយបានច្រើនកុះករ ។

-ទំនាក់ទំនងជាមួយខេត្តសម្ព័ន្ធមិត្ត និងខេត្តដែលពាក់ព័ន្ធ ដើម្បីរៀបចំពិធីនេះដំណើរការបានលទ្ធផលល្អប្រសើរ ។

-គៀងគរ ប្រមូលទូកពីគ្រប់ឃុំ សង្កាត់ រៀបចំផ្លូវផ្គង់ទូកសម្រាប់ប្រណាំង ដោយមានមន្ទីរ អង្គភាព ក្រុមការងារគ្រប់លំដាប់ថ្នាក់ជួយគាំទ្រ ដើម្បីប្រកួតប្រជែងយកជ័យលាភីរបស់ឯកឧត្តម **ចម ប្រសិទ្ធ** និងលោកជំទាវ **ទេព បុប្ផាប្រសិទ្ធ** ។

-រៀបចំប្រកួតតាមលក្ខណៈប្រពៃណីជាតិ ដោយធានាតាមស្តង់ដាប្រកួត ។

-រៀបចំកន្លែងសម្រាប់ចេញដំណើរ និងទីផ្តាច់ព្រ័ត្រ សម្រាប់ការប្រណាំង ។

-រៀបចំចំណុះទូក " ចំនួនកីឡាករ " ។

-រៀបចំទូក ឬមធ្យោបាយផ្សេងៗចល័តជួយសង្គ្រោះក្នុងពេលមានហេតុការណ៍អ្វីកើតឡើងជាយថាហេតុ ។

-គ្រប់គ្រងទូកដែលបានចូលរួមក្នុងការប្រណាំងទាំងមូលអោយបានច្បាស់លាស់ ពិតប្រាកដ ។

-រៀបចំរបៀបវារៈនៃការប្រណាំង ។

-រៀបចំក្រុមធ្វើអត្ថាធិប្បាយមុនការប្រកួត និងក្នុងពេលប្រកួត ។

-រៀបចំលទ្ធផលនៃការប្រកួតជូនគណៈកម្មការ ។

ង-**អនុគណៈកម្មការសន្តិសុខ សណ្តាប់ធ្នាប់ និងសុខភាព** :

ង.១ **សមាសភាព** :

| | | | | |
|---|---|---|---|---|
| ១-លោកឧ.ត្រី | **អ៊ុច** | **សំអុល** | ស្នងការនគរបាលខេត្ត | ជាប្រធាន |
| ២-លោកឧ.ត្រី | **ជួន** | **សុផល** | មេបញ្ជាការតំបន់ប្រតិបត្តិការសឹកខេត្ត | ជាអនុប្រធាន |
| ៣-លោកឧ.ត្រី | **ឆា** | **គៀត** | មេបញ្ជាការកងរាជអាវុធហត្ថខេត្ត | ជាសមាជិក |
| ៤-លោក | **ទេព** | **យុទ្ធី** | អភិបាលស្រុកដំណាក់ចង្អើរ | ជាសមាជិក |
| ៥-លោក | **ទិន** | **ទិនដា** | អភិបាលក្រុងកែប | ជាសមាជិក |
| ៦-លោកវ.ទោ | **ពេញ** | **តារ៉ូ** | មេបញ្ជាការវរៈសេនាតូចលេខ៤៣០ នគរបាលព្រំដែនទឹក | ជាសមាជិក |
| ៧-លោក | **ម៉ែន** | **សុធីរ** | ប្រធានមន្ទីរសុខាភិបាល | ជាសមាជិក |
| ៨-លោក | **នួន** | **សេង** | អនុប្រធានមន្ទីរសុខាភិបាលខេត្ត | ជាសមាជិក |
| ៩-លោក | **មុំ** | **ស៊ីថា** | អធិការនគរបាលក្រុងកែប | ជាសមាជិក |
| ១០-លោក | **ម៉ែន** | **សុធន** | មេបញ្ជាការកងរាជអាវុធហត្ថក្រុង | ជាសមាជិក |
| ១១-លោក | **ខៀវ** | **ម៉ុនរិទ្ធ** | មេបញ្ជាការផ្នែកសឹករងក្រុង | ជាសមាជិក |

ង.២ **ភារកិច្ច** :

-រៀបចំសណ្តាប់ធ្នាប់ របៀបរៀបរយការពារសុវត្ថិភាពជូនអង្គពិធីគ្រប់ទិដ្ឋភាព ។

-ធ្វើផែនការសកម្មភាពការពារសន្តិសុខ ក្នុងពិធី ( ទីតាំងប្រណាំងទូក និងទីតាំងតាំងពិពរណ៍) ។

-រៀបចំផ្លូវធ្វើដំណើរចេញ ចូលទៅកាន់វេទិការឱ្យបានសមស្រប ដើម្បីបញ្ចៀសការកកស្ទះ និងធានាសុវត្ថិភាពនៅក្នុងពេលដំណើរការប្រណាំង ។/.

-ត្រៀមរៀបចំអោយមានមន្ត្រីសុខាភិបាល មធ្យោបាយ ឧបករណ៍ និងថ្នាំពេទ្យសម្រាប់ការសង្គ្រោះឱ្យបានគ្រប់គ្រាន់ ។

-រៀបចំទីតាំងសម្រាប់ក្រុមគ្រូពេទ្យ ដោយដាក់ស្លាកសញ្ញាសម្គាល់ឱ្យបានច្បាស់ និងងាយស្រួលមើល ។

**ច.លេខាធិការដ្ឋានគណៈកម្មការរៀបចំការប្រណាំងទូក**

**ច.១ សមាសភាព :**

| | | | |
|---|---|---|---|
| ១-លោក | **ហៀម យួន** | នាយករដ្ឋបាលសាលាខេត្ត | ជាប្រធាន |
| ២-លោក | **អ៊ុច ផុន** | នាយករងរដ្ឋបាលសាលាខេត្ត | ជាអនុប្រធាន |
| ៣-លោក | **នូ សំណាត** | នាយកទីចាត់ការរដ្ឋបាលសាលាខេត្ត | ជាសមាជិក |
| ៤-លោក | **គីត សារ៉េត** | នាយករងទីចាត់ការផែនការ និងវិនិយោគខេត្ត | ជាសមាជិក |
| ៥-លោកស្រី | **យ៉ែម គីមហេង** | នាយករងទីចាត់ការរដ្ឋបាលសាលាខេត្ត | ជាសមាជិក |
| ៦-លោកស្រី | **សូ សារិកា** | ប្រធានការិយាល័យទំនាក់ទំនងសាធារណៈ និងសហប្រតិបត្តិការអន្តរជាតិសាលាខេត្ត | ជាសមាជិក |
| ៧-លោក | **ឌុល សាន់** | ប្រធានការិយាល័យសរុប និងព័ត៌មានសាលាខេត្ត | ជាសមាជិក |
| ៨-លោក | **សាំង សារឿន** | អនុប្រធានការិយាល័យសរុប និងព័ត៌មានសាលាខេត្ត | ជាសមាជិក |

**ច.២ ភារកិច្ច :**

-រៀបចំសុន្ទរកថាស្វាគមន៍របស់ឯកឧត្តមអភិបាលខេត្ត ។

-រៀបចំរបៀវារៈ នៃអង្គពិធី ។

-រៀបចំលិខិតអញ្ជើញ និងលិខិតជូនដំណឹង កម្មវិធីលម្អិត និងពិធីប្រណាំង ជូនដល់ខេត្តសម្ព័ន្ធមិត្ត និងខេត្តដែលពាក់ព័ន្ធក្នុងការចូលរួមប្រណាំងទូក ។

-បូកសរុបលទ្ធផល នៃអង្គពិធីទាំងមូលជូនថ្នាក់ដឹកនាំខេត្ត ។

***ប្រការ៤:*** ក្រៅពីភារកិច្ចដែលបានកំណត់ អនុគណៈកម្មការនីមួយៗ មានភារកិច្ចផ្សេងៗទៀត តាមការប្រគល់ពីលោកប្រធានគណៈកម្មការ ដើម្បីឆ្លើយតបសំណូមពរការងារ ។

***ប្រការ៥:*** ប្រធានអនុគណៈកម្មការនីមួយៗ ត្រូវធ្វើលិខិតបង្គាប់ការបែងចែកភារកិច្ចជាក់ស្តែងជូនសមាជិកឱ្យទទួលខុសត្រូវ។

***ប្រការ៦:*** ប្រធាន អនុប្រធាន និងសមាជិកគណៈកម្មការ អនុគណៈកម្មការមានសិទ្ធិប្រើប្រាស់មន្ត្រីក្រោមឱវាទទៅតាមតម្រូវការការងារអោយសម្រេចបានលទ្ធផលល្អប្រសើរ ។

***ប្រការ៧:*** លោកនាយករដ្ឋបាលសាលាខេត្ត លោកនាយកគ្រប់ទីចាត់ការរបស់សាលាខេត្ត លោក លោកស្រីប្រធានមន្ទីរអង្គភាពជុំវិញខេត្ត គណៈអភិបាលក្រុង ស្រុក និងអស់លោក លោកស្រី ក្នុងប្រការ ១ និងប្រការ ៣ ខាងលើមានភារកិច្ចអនុវត្តឱ្យទទួលបានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។/

កែប.ថ្ងៃទី........ខែ...........ឆ្នាំ ២០១០

**អភិបាលខេត្ត**

***កន្លែងទទួល***

-ក្រសួងមហាផ្ទៃ

-ក្រសួងពាណិជ្ជកម្ម

-ក្រុមប្រឹក្សាខេត្ត

" **ដើម្បីជូនជ្រាប** "

-ដូចប្រការ៧ " **ដើម្បីអនុវត្ត** "

-ឯកសារ-កាលប្បវត្តិ